CARITAS CHRISTI URGET NOS

# ពិធីប្រសិទ្ធីពរលើគ្រូអប់រំជំនឿក្នុងមណ្ឌលសកម្មភាពទន្លេមេគង្គនិងទន្លេបាសាក់
# ធ្វើនៅព្រះសហគមន៍សន្តហ្វ្រង់ស្វ័រសាវីយេ ចំប៉ា
# មេគង្គ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២
# "គ្រូអប់រំជំនឿជាអ្នកផ្តល់ជីវិតនៃជំនឿ"

**អត្ថបទទី១៖ អេភេសូ ១,១១-១៤**

បងប្អូនបានស្តាប់ព្រះបន្ទូលនៃសេចក្តីពិត ជាដំណឹងល្អដែលសង្គ្រោះបងប្អូន។ អភ ១,១៣

**ដំណឹងល្អ៖ លូកា ៨,៤-១៥**

គ្រាប់ពូជជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ លក ៨,១១

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះ យើងបានស្តាប់ព្រះបន្ទូលមួយដែលណែនាំឱ្យយើង ចូលនៅក្នុងរបៀបដែលព្រះសហគមន៍ត្រូវតែអប់រំជំនឿ។ យើងបានឃើញម្ចាស់ចំការគាត់បានចេញពីព្រលឹម គាត់បានសាបព្រោះមានគ្រាប់ពូជខ្លះធ្លាក់ក្នុងដីដែលមានសុទ្ធតែថ្ម វាដុះតិចៗប៉ុន្តែនៅពេលត្រូវកំដៅថ្ងៃវាងាប់អស់ហើយ ដោយសារឥតមានឫសដើម្បីចាក់ជ្រៅ។ មានគ្រាប់ពូជខ្លះធ្លាក់នៅលើដីដែលមានបន្លា វាដុះមិនកើតទេ ដោយសារបន្លាណែនាំឱ្យពូជដុះមិនបាន ឥតមានដង្ហើម ឥតមានអ៊ុកស៊ីសែន ឥតមានខ្យល់ ឥតមានពន្លឺ ណែនាំឱ្យវាងាប់អស់។ មានគ្រាប់ពូជខ្លះ ធ្លាក់នៅលើដីដែលមានជីជាតិល្អ វាចាប់ផ្តើមលូតលាស់ណែនាំឱ្យមានផ្លែយ៉ាងច្រើន។

បងប្អូនជាទីស្រឡាញ់ គឺព្រះជាម្ចាស់ដែលសាបព្រោះ ព្រះជាម្ចាស់សាបព្រោះនៅក្នុងដួងចិត្តរបស់យើងទាំងអស់ ជាក្មេងក្តី ជាយុវជនក្តី ជាគ្រូអប់រំជំនឿក្តី ជាគ្រីស្តបរិស័ទក្តី ព្រះជាម្ចាស់សាបព្រោះ។ ប៉ុន្តែ ក្រោយមកអាស្រ័យលើដួងចិត្តរបស់យើង ជំនឿរបស់យើង ជីវិតរបស់យើងប្រចាំដើម្បីឱ្យគ្រាប់ពូជដែលព្រះជាម្ចាស់បានសាបព្រោះនៅក្នុងដួងចិត្តរបស់យើង អាចលូតលាស់។ ប្រសិនបើជីវិតរបស់យើងឆ្ងាយពីព្រះជាម្ចាស់ ដូចបន្លាបន្តិចម្តងៗគ្រាប់ពូជដែលព្រះជាម្ចាស់បានសាបព្រោះងាប់អស់ហើយ។ ដោយសារ យើងរវល់រកស៊ី យើងរវល់ដើរលេង យើងរវល់រឿង

លោកីយ៍ យើងភ្លេចចូលព្រះសហាគមន៍អស់ហើយ។ ប្រសិនបើ ធ្លាក់នៅក្នុងជីវិតរបស់យើងយូរៗម្តងនឹកឃើញ ចូលព្រះវិហារ ស្តាប់ព្រះបន្ទូលផង លេងទូរស័ព្ទផង សូត្រធ្ម៌ប៉ុន្តែនឹកឃើញរឿងផ្សេងៗ ដូចជាមិនបានចាក់នៅក្នុងដីយ៉ាងជ្រៅទេ បន្តិចម្តងៗស្វិតទៅៗ។ ផ្ទុយទៅវិញ ប្រសិនបើនៅក្នុងដីល្អដែលមានជីជាតិ យើងដឹងថាវាលូតលាស់។ ប៉ុន្តែ ជីមកពីគ្រូអប់រំជំនឿយកចិត្តទុកដាក់ថែទាំ បង្រៀន លើកទឹកចិត្ត ដើម្បីឱ្យគ្រីស្តបរិស័ទម្នាក់ៗត្រូវតែមានបញ្ហានៅក្នុងជីវិត អំណរសប្បាយ អាចទៅមុខបាន។

ដូច្នេះ តួនាទីដែលយើងទទួលថ្ងៃនេះមិនមែនជំនួសព្រះជាម្ចាស់ទេ ព្រះជាម្ចាស់សាបព្រោះ ព្រះជាម្ចាស់ថែរក្សា ព្រះជាម្ចាស់ប្រទានជំនឿមែន។ ប៉ុន្តែ យើងធ្វើដូចម្តេចដើម្បីឱ្យបងប្អូនដែលនៅក្នុងក្រុមអប់រំជំនឿរបស់យើង អាចលូតលាស់នៅក្នុងជីវិតប្រចាំជាគ្រីស្តបរិស័ទ។ ដើម្បីឱ្យព្រះសហាគមន៍របស់យើងទៅជាដើមឈើមួយយ៉ាងស្អាត ដែលមានផ្កាយ៉ាងច្រើន ដែលមានផ្លែយ៉ាងច្រើន ដែលមានទីលំនៅសម្រាប់បក្សាបក្សីទាំងអស់។ ដើម្បីឱ្យព្រះសហាគមន៍របស់យើង ទៅជាគ្រួសារមួយដែលចេះយល់ចិត្តគ្នានៅក្នុងព្រះយេស៊ូគ្រីស្ត។

ដូច្នេះ ថ្ងៃនេះខ្ញុំអធិដ្ឋានដើម្បីឱ្យយើងជាបូជាចារ្យ រួមជាមួយបងប្អូនដែលជាបព្វជិតបព្វជិតា ជាគ្រូអប់រំជំនឿ ឱ្យយើងធ្វើដំណើររួមជាមួយគ្នា ដើម្បីឱ្យព្រះសហាគមន៍របស់យើងចាក់គ្រឹស្តយ៉ាងជ្រៅនៅក្នុងការអធិដ្ឋាន នៅក្នុងជីវិតជាគ្រីស្តបរិស័ទដោយចេះស្រឡាញ់និងលើកលែងទោស។ នៅក្នុងជីវិតជាគ្រីស្តបរិស័ទភ្ជាប់ជាមួយព្រះជាម្ចាស់ ដើម្បីឱ្យព្រះសហាគមន៍របស់យើងពោរពេញដោយជីវិត ពោរពេញដោយអំណរសប្បាយដ៏ពេញលក្ខណៈ ដែលមកពីព្រះវិញ្ញាណដ៏វិសុទ្ធផ្ទាល់។ អាម៉ែន។៚

+ លោកអភិបាល អូលីវីយេ ជ្មឹតហាស្លេ
អភិបាលព្រះសហាគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ

https://youtu.be/BMsBCM1gPbs